# សេចក្តីអំពាវនាវ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ចំពោះព្រះសង្ឃខ្មែរនៅបរទេស សូមរក្សាលក្ខណៈជាព្រះសង្ឃខ្មែរ

Website: www.hoksavann.org

ថ្ងៃទី២៥ ធ្នូ ២០០៤

ព្រះពុទ្ធសាសនាថេរវាទមានធម៌វិន័យបរិសុទ្ធមិនកែប្រែ គឺបន្ទាប់ពីព្រះពុទ្ធបរិនិព្វានទៅ ព្រះអរហន្តទាំងឡាយបានធ្វើសង្គាយនាផ្ទៀងផ្ទាត់ធម៌វិន័យតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ទើបសរសេរជាលាយលក្ខអក្សរក្នុងគម្ពីរព្រះត្រៃបិដក ដែលពុទ្ធបរិស័ទលើកយកមកសិក្សានិងប្រតិបត្តិតាមសព្វថ្ងៃនេះ ។ ប្រទេសដែលគោរពព្រះពុទ្ធសាសនាថេរវាទមានប្រទេសកម្ពុជា ថៃ លាវ ភូមា ស្រីលង្កា និងជនជាតិខ្លះទៀតនៅទ្វីបអាស៊ីនិងទ្វីបអឺរ៉ុប ។ ពាក្យថាថេរវាទប្រែថា ពាក្យរបស់ព្រះថេរៈ ជាព្រះអរហន្តដែលបានធ្វើសង្គាយនាផ្ទៀងផ្ទាត់ធម៌វិន័យតានពាក្យរបស់ព្រះពុទ្ធមិនកែប្រែ ពីព្រះពុទ្ធសំដែងយ៉ាងណារក្សាទុកយ៉ាងនោះ។ ដូច្នេះប្រទេសដែលគោរពព្រះពុទ្ធសាសនាថេរវាទ មានធម៌វិន័យរបស់ព្រះពុទ្ធដូចគ្នា ខុសគ្នាតែត្រង់លើកយកមកប្រតិបត្តិនិងទំនៀមទំលាប់ពិធីកម្មនៃប្រទេសនីមួយៗផ្សេងៗគ្នាប៉ុណ្ណោះ ។

សូមអំពាវនាវចំពោះព្រះសង្ឃខ្មែរ ដែលនិមន្តមកសិក្សានៅបរទេស មានព្រះសង្ឃមកសិក្សាប្រះពុទ្ធសាសនាក្នុងប្រទេសដែលកាន់ព្រះពុទ្ធសាសនាថេរវាទ សូមរក្សាលក្ខណៈជាព្រះសង្ឃខ្មែរ ព្រោះបើទោះបីកាន់ព្រះពុទ្ធសាសនាថេរវាទដូចគ្នា ប៉ុន្តែមានប្រពៃណីទំនៀមទំលាប់ផ្សេងគ្នា ។ ប្រទេសកាន់ព្រះពុទ្ធសាសនាថេរវាទ ដែលព្រះសង្ឃខ្មែរទៅសិក្សា គឺប្រទេសថៃ ប្រទេសស្រីលង្កា ប្រទេសភូមា និងប្រទេសឥណ្ឌា ។ ចំណែកព្រះសង្ឃខ្មែរទៅសិក្សានៅប្រទេសចិនតៃវ៉ាន់ ដែលជាប្រទេសកាន់ព្រះពុទ្ធសាសនាមហាយាន ដែលមានការកែប្រែធម៌វិន័យខុសគ្នាពីព្រះពុទ្ធសាសនាថេរវាទ ដូច្នេះព្រះសង្ឃខ្មែរដែលទៅសិក្សានៅប្រទេសនោះ គប្បីអនុវត្តខមួយទៀត លើសព្រះសង្ឃដែលទៅសិក្សានៅប្រទេសដែលកាន់ពុទ្ធសាសនាថេរវាទ គឺកុំធ្វើតាមលក្ខណៈព្រះសង្ឃមហាយាន គប្បីធ្វើតាមតែលក្ខណៈព្រះសង្ឃថេរវាទជាលក្ខណៈខ្មែរ ។ បានសេចក្តីថា នាំគ្នាទៅសិក្សាក្រេបយកចំណេះវិជ្ជាពីប្រទេសគេ ប៉ុន្តែត្រូវរក្សាលក្ខណៈនិងតម្លៃជាព្រះសង្ឃខ្មែរ ។ មួយទៀត បើបានចំណេះវិជ្ជាហើយត្រឡប់មកមាតុប្រទេសវិញ កុំចម្លងយកទំនៀមទំលាប់នៃប្រទេសទាំងនោះមកអនុវត្តក្នុងប្រទេសរបស់ខ្លួន ដែលនាំឲ្យបាត់បង់នូវអត្តសញ្ញាណនៃព្រះពុទ្ធសាសនាខ្មែរ ។ ប្រទេសកម្ពុជាសព្វថ្ងៃនេះមានឯកភាពល្អណាស់ក្នុងការអនុវត្តន៍ព្រះពុទ្ធសាសនា បើយកទំនៀមទំលាប់ប្រពៃណីពីបរទេសមកអនុវត្ត ផ្ទុយពីទំនៀមទំលាប់របស់ខ្លួន នាំឲ្យបែកគណៈនិកាយផ្សេងទៀត ដែលជាហេតុនាំឲ្យបង្កើតជម្លោះបែកបាក់សាមគ្គី ។

តាមការសង្កេត ព្រះសង្ឃខ្មែរកម្ពុជាក្រោមនៅតែរក្សាលក្ខណៈជាព្រះសង្ឃខ្មែរ ទោះនៅកម្ពុជាក្រោមក្តី ចូលមកគង់នៅកម្ពុជាកណ្តាលក្តី មករស់នៅបរទេសក្តី ។ ចំណែកព្រះសង្ឃខ្មែរដែលគង់នៅប្រទេសថៃអស់ពេលយូរ ត្រូវពុទ្ធបរិស័ទខ្មែរផានាមកគង់នៅសហរដ្ឋអាមេរិក កាណាដា បារាំង អូស្ត្រាលី មានព្រះសង្ឃភាគច្រើននៅមានលក្ខណៈជាព្រះសង្ឃខ្មែរ ប៉ុន្តែមានព្រះសង្ឃមួយភាគតូចបានចម្លងយកសាសនាពិធីរបៀបថៃមកអនុវត្តក្នុងសង្គមខ្មែរ ។ របៀបខុសគ្នានៃសាសនាពិធីខ្មែរនិងថៃខុសគ្នា គឺពេលសូត្រធម៌ជូនពរពុទ្ធបរិស័ទដែលប្រគេនបច្ច័យ ៤ ព្រះសង្ឃខ្មែរពុំលើកព្រះហត្ថសំពះទេ ចំណែកព្រះសង្ឃថៃលើកព្រះហស្តសំពះទៅរកគ្រហស្ថ; ព្រះសង្ឃថៃ ពេលសូត្រធម៌បង្សុកូលកាន់ខ្សែអំបោះដែលបន្តពីសព ឬពីធាតុ ឬពីរូបថតអ្នកស្លាប់ ចំណែកព្រះសង្ឃខ្មែរមិនកាន់ខ្សែអំបោះដូច្នេះទេ ព្រោះយល់ថាការបង្សុកូល គឺជាការសូត្រធម៌ធម្មសំវេគសំរាប់ពិចារណា ឯការឧទ្ទិកុសល គឺសំរេចលើគ្រួសារសព ដែលផ្សាយតាមផ្លូវមនោទ្វារ គឺផ្លូវចិត្ត ពុំមែនផ្សាយតាមខ្សែអំបោះទេ; ព្រះសង្ឃថៃមុនឆាន់ចង្ហាន់តែងសូត្រអជ្ជៈ ចំណែកព្រះសង្ឃខ្មែរមិនសូត្រទេ ព្រោះយល់ថាធម៌អជ្ជៈជាតួបច្ចវេក្ខណញ្ញាណ គឺឲ្យព្រះសង្ឃពិចារណានៅពេលទទួលឬពេលបរិភោព និងប្រើប្រាស់បច្ច័យ៤កុំឲ្យជាប់តណ្ហាក្នុងការប្រើប្រាស់និងការបរិភោគ ដូចក្នុងសីល៤របស់ភិក្ខុសង្ឃក្នុងខមួយចែងថា ព្រះសង្ឃទទួលប្រើប្រាស់បច្ច័យ៤ បរិសុទ្ធដោយការពិចារណា ដូច្នេះពុំមែនបរិសុទ្ធដោយការសូត្រទេ ។ អាចសូត្របានដើម្បីឲ្យចាំ ក្រៅពីចំពោះមុខគ្រហស្ថដូចសូត្រពេលថ្វាយបង្គំព្រះរតនត្រ័យជាដើម ។ ចម្លែកមួយទៀត សូត្រធម៌ជូនពរដែលឥតមានអ្នកស្តាប់នៅពេលនោះ នេះក៏ជាការឆ្គង ព្រោះការសូត្រធម៌ជូនពរក្នុងបាលីថាបត្តានុមោទនា គឺត្រេកអរចំពោះអ្នកធ្វើកុសលជាការលើកទឹកចិត្ត ចុះបើគ្មានអ្នកស្តាប់នៅទីនោះទេ តើសូត្រដើម្បីអ្វី ? ដើម្បីឲ្យរួចចាកទោសកុំឲ្យឥណបរិភោគ ត្រូវពិចារណាជាបច្ចវេក្ខណញ្ញាណ ក្នុងការប្រើប្រាស់បច្ច័យ៤ដែលគេប្រគេននោះវិញ ។ ព្រះសង្ឃជាឧត្តមភេទ ជាភេទដ៏ខ្ពង់ខ្ពស់សូម្បីព្រះមហាក្សត្រស្តេចផែនដីក៏ថ្វាយបង្គំដែរ តែបែរជាមានព្រះសង្ឃខ្លះ មិនត្រឹមតែព្រះមហាក្សត្រលើកព្រះហស្តសំពះៗតបវិញទេ ថែមទាំងលើកដៃសំពះគ្រហស្ថទូទៅពេលគ្រហស្ថលើកដៃសំពះ នេះជាការរណោបរណាបយកបុណ្យស័ក្តិនិងលាភសក្ការៈខុសធម៌វិន័យ ដោយបំពុះតម្លៃខ្លួនឯង និងនាំឲ្យខូចតម្លៃព្រះពុទ្ធសាសនាទៀត ។៚

❏